ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦៨៨០ អយក.ជាក

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ថវិកាបុរេប្រទានសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ ដើម្បីចំណាយលើកិច្ចដំណើរការនិងឧបត្ថម្ភជូនគណៈកម្មការចេញសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០។

**យោង ៖** -លិខិត១០២២៥ សហវ.អថ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-សេចក្តីណែនាំលេខ៨៣ អយក.សជណ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានបើកថវិកាបុរេប្រទានពីអគ្គនាយកដ្ឋានរតនាគារជាតិនិងរតនាគាររាជធានី ខេត្ត តាមស្មារតីនៃលិខិតលេខ៨៤០០ សហវ.អថ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ មានចំនួន២១ ១៥២ ៩៩៣ ២០០រៀល (ម្ភៃមួយប៊ីលាន មួយរយហាសិបពីរលាន ប្រាំបួនរយកៅសិបបីពាន់ ពីររយរៀលគត់) សម្រាប់ចំណាយក្នុងការរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៩-២០២០ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០។ ទន្ទឹមនឹងនេះ ក្រសួងក៏បានទទួលអនុសាសន៍ដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៩-២០២០ ជាប់ជាស្ថាពរសម្រាប់បេក្ខជនទាំងអស់ ដែលបានចុះឈ្មោះប្រឡង គ្មានការកំណត់និទ្ទេស ដោយស្ថិតក្នុងស្ថានការណ៍មិនទាន់ច្បាស់លាស់នៃការរីករាលដាលជំងឺកូវីដ១៩(COVID-19) កំពុងរាតត្បាតក្នុងព្រឹត្តិការណ៍សហគមន៍បច្ចុប្បន្ន។

ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យឃើញថា ដោយមានតម្រូវការចាំបាច់ក្នុងការចំណាយសម្រាប់កិច្ចដំណើរការនិងបង្កើតគណៈកម្មការចេញសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីរៀបចំផលិតសន្លឹកសញ្ញាបត្រផ្តល់ជូនបេក្ខជនជាប់ជាស្វ័យប្រវត្តិចំនួនសរុប ១២១ ១០៧នាក់ ឱ្យទាន់ពេលវេលាក្នុង



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ការប្រើប្រាស់តាមតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំអនុញ្ញាតជាគោលការណ៍ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រើប្រាស់ថវិកាបុរេប្រទានឆ្នាំ២០២០ សម្រាប់ចំណាយក្នុងកិច្ចដំណើរការ និងឧបត្ថម្ភជូនគណៈកម្មការចេញសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ រីឯការកំណត់និយាមប្រើប្រាស់ រយៈពេលបំពេញការងារ និងប្រាក់ឧបត្ថម្ភរបស់គណៈកម្មការ មានដូចខាងក្រោម៖

**១**-ការកំណត់និយាមនិងរយៈពេលបំពេញការងារ៖

-ប្រធាន ចំនួនៈ០១រូប

-អនុប្រធាន ចំនួនៈ០២រូប

-សមាជិក ចំនួនៈ ០១នាក់ ក្នុងបេក្ខជន៣ ០០០នាក់។ ដោយឡែក គណៈកម្មការត្រូវបំពេញការងាររយៈពេលចំនួន២០ថ្ងៃ។

**២**-ការកំណត់ប្រាក់ឧបត្ថម្ភ ៖ ចំពោះប្រាក់ឧបត្ថម្ភគណៈកម្មការចេញសញ្ញាបត្រ ត្រូវផ្តល់ជូនតាមរបបម៉ៅការ៖

-ប្រធាននិងអនុប្រធាន ចំនួនៈ ៣ ០០០ ០០០រៀល/ម្នាក់

-សមាជិក ចំនួនៈ ១ ៣០០ ០០០រៀល/ម្នាក់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពនិងអនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ ច័ន្ទ ១០កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

" ដើម្បីជ្រាបជាព័ត៌មាន "

-កាលប្បវត្តិ

-ឯកសារ.នាយកដ្ឋានហិរញ្ញវត្ថុ